

# សត្យា ប្រយ័ត្ន!

Let's Read
The Asia Foundation



សត្យា គឺជាក្មេងមិនចេះនៅស្ងៀម។ សត្យា រត់ លោត បង្វិលខ្លួន រមៀលខ្លួន...ហើយដួល។



ឪពុករបស់ សត្យា ប្រាប់ថា "សត្យា អង្គុយឱ្យស្ងៀមបន្តិចមើល!
"

បងស្រីរបស់ សត្យា ប្រាប់ថា "សត្យា ប្រសិនបើដួលឈឺ កុំមក
យំដាក់បង!"





តារបស់សត្យាប្រាប់ថា ”សត្យា កុំធ្វើឱ្យបែកអីឱ្យសោះ!”
អ្នកគ្រូរបស់សត្យាប្រាប់ថា ”សត្យា កូនកំពុងតែរំខានគេរៀន
ហើយ!”





ប៉ុន្តែ សត្យា នៅតែមិនចេះនៅស្ងៀម ដៃជើងនៅមិនស្ងៀមទេ។



ថ្ងៃនេះជាថ្ងៃអាទិត្យ ជាថ្ងៃដែលសត្យាចូលចិត្តបំផុត។ ថ្ងៃអាទិត្យ នេះ សត្យា ទៅចម្ការជាមួយម្តាយរបស់ខ្លួន។ ម្តាយរបស់សត្យា មានការងារត្រូវធ្វើនៅទីនោះ។



ទៅចម្ការនោះ សត្យា ត្រូវដើរឆ្ងាយកាត់ផ្លូវស្ងាត់ កាត់វាល កាត់ព្រៃក្រាស់ និងអូរដែលមានទឹកហូរឥតឈប់។



សត្វាលោតដូចទន្សាយ ហើយរត់លឿនដូចក្តាន់។
ម្តាយរបស់សត្វាប្រាប់ថា ”ភក់ល្បៀច ប្រយ័ត្នផងកូន!”



សត្យាវារដូចក្អែប លូនដូចពស់។
ម្តាយរបស់សត្យាប្រាប់ថា ”ប្រយ័ត្នបន្លាកូន!”



សត្យាលោតតោងដូចពីងពាង ហើយលោតផ្លោះដូចស្វា។
ម្ដាយរបស់សត្យាប្រាប់ថា ”កូនតោងមែកណាដែលមាំណាំ!”



សត្យា ហែលទឹកដូចទា ដូចកង្កែប។
ម្ដាយរបស់ សត្យា ប្រាប់ថា ”កូន នៅលេងតែទឹករាក់បានហើយ ដឹងអត់?”



សត្យាវារទ្បើងដូចបង្គួយ ហើយលោតដូចពពែ។
ម្តាយរបស់សត្យាប្រាប់ថា ”កូន កុុំឱ្យរអិលដួលណា!”



សត្យា ត្រវីដៃទាំងពីរដូចស្លាបបក្សី ចង់ហើរទៅឆ្ងាយ។ សត្យា ស្រមៃចង់ចេះហើរសំកាំងដូចសត្វត្មាត។



ពេលល្ងាច ព្រះអាទិត្យចាប់ផ្ដើមលិច ចង្រិតក៏ចាប់ផ្ដើមស្រែកយំ។ ចំណែកឯ សត្យា ក៏ត្រូវដល់ពេលត្រឡប់ទៅផ្ទះវិញ។ សត្យា អស់កម្លាំង ហើយឡើងជិះលើខ្នងម្ដាយ។ សត្យា និងម្ដាយ ត្រឡប់មកផ្ទះវិញ ដើរកាត់ផ្លូវឡើងចុះ កាត់វាល កាត់ព្រៃ កាត់អូរ។



ដល់ផ្ទះ ឪពុក តា និងបងស្រី ក្រឡេកមើលសត្វា ឃើញប្រ
លាក់ភក់និងមានស្នាមជាំ។ ពួកគាត់នាំគ្នាផ្ទុះសំណើច។



តា ងូតទឹកឱ្យសត្យា។ ចំណែកឯឪពុក ចម្អិនម្ហូបឱ្យសត្យា។ ពេលចូលគេង បងស្រីនិយាយរឿងដែលសត្យាចូលចិត្តបំផុតឱ្យសត្យាស្ដាប់។



សត្យា យល់សប្តិឃើញរត់លេង លោត បង្វិលខ្លួន រមៀលខ្លួន...



...និងចេះហោះហើរ។





តើសត្វ បក្សី សត្វល្អិត ធ្វើដំណើរយ៉ាងណា? អូ! ពួកវាធ្វើដំណើរដូចអ្វីដែលសត្វា បានធ្វើដែរ។ តើប្អូន ដឹងថា សត្វបក្សី និងសត្វល្អិត ធ្វើដំណើរផ្សេងគ្នា ដោយសារមូលហេតុផ្សេងគ្នាដែរឬអត់? ដូចយើងដែរ ពួកវាធ្វើដំណើរភាគច្រើនដើម្បីទៅរកអាហារឆ្ងាញ់ ទីលំនៅកក់ក្តៅ និងគ្រួសារកក់ក្តៅ។ ពួកវាខ្លះ ធ្វើដំណើរផ្លាស់ទីដើម្បីគេចកុំឱ្យសត្វផ្សេងចាប់ស៊ី។ ចូររកមើលរបៀបធ្វើដំណើររបស់សត្វខ្លះ។





ផ្សោត គេស្គាល់ច្រើនដោយសាររបៀបដែលវាលោតចេញពីទឹក។ តើប្អូនអាចលោតបានទេ? ខ្លារខិន(ឈីតា) គឺជាប្រភេទសត្វលើគោកដែលរត់លឿនជាងគេបំផុត។ វារត់លឿនមែនទែនជាពិសេសនៅពេលដែលវារត់ដេញចាប់សត្វផ្សេង។ តើប្អូនអាចរត់លឿនបានទេ?







ក្ដាមអាចដើរចំហៀងបាន។ តើប្អូនអាចដើរចំហៀងបានដែរទេ? កណ្ដូបអាចលោតបានខ្ពស់ ជាពិសេសនៅពេលដែលវាគេចកុំឱ្យសត្វផ្សេងចាប់ស៊ី។ តើប្អូនអាចលោតខ្ពស់បានដែរទេ?ខ្យងវារយឺតៗណាស់។ តើប្អូនអាចវារយឺតៗដូចខ្យងបានទេ?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Satya, Watch Out!*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Hor Pheahong, Somey Chheang, and SOEURM Kakada